# ២១ - រឿង ខ្លា ស្វា និង ទន្សាយ



Gratis Garnier Produkte
Jetzt gratis Produkte testen.
Entdecke Garnier !

មានសត្វខ្លាមួយ វាដាច់សង្វែង ដើររកចាប់អ្វីមិនបានសោះ ខំដើរស្វែងណាស់ ៗ ទៅប្រទះនឹងសត្វអកមួយ កំពុងតែយំពុសូរអកអូៗ ទំលើដើមព្រឹក្សាមួយនៅមាត់ត្រពាំង ខ្លាក្រឡេកមើលទៅឃើញគិតក្នុងចិត្តថា « ធ្វើម្ដេចនឹងចាប់អានេះបានហ្ន ! បើវានៅខ្ពស់ម្ល៉េះ ? បើអញឡើងទៅ មុខជាវាឃើញ ហើយហើរទៅកាលណានឹងចាប់វាបាន?»។ ខ្លាអង្គុយចាំមើលកិច្ចកលសត្វអកនោះ ។ ឯសត្វអកនោះកាលណាទំហើយ ភ្នែកវាតែងរំពៃមើលទៅបង្កៃត្រី ក្រែងមានត្រីបន្ទៀកខ្លួនឡើងនឹងចាប់ ។ យូរបន្តិចមានត្រីមួយផុសឡើងពីក្នុងទឹក , អកស្ទុះទៅចាប់បានត្រីនោះ យកមកធ្វើជាចំណីវាទៅ ។ ខ្លាឃើញអកធ្វើដូច្នោះ ក៏គិតក្នុងចិត្តថា «ឃើ ! អាអកនេះវាអង្គុយតែស្ងៀមសោះ ស្រាប់តែមានត្រីហែលក្នុងត្រពាំងនោះ វាស្ទុះទៅចាប់បានមួយរំពេចយកមកក្រអែះ មិននឿយហត់ប៉ុន្មានសោះ មិនព្រួយដូចជាខ្លួនអញ ខំដើរស្វែងរកស្ទើរស្លាប់មិនងាយបាន , អានេះអង្គុយធ្វើប្រងុក ៗ ចាប់បានភ្លាមៗ ហើយវាមិនលំបាកលបលំបាកឱនក្រាបទៀតផង, បើដូច្នេះអញគិតធ្វើដូចសត្វអកនេះវិញស្រួលជាង » ។ ខ្លាគិតដូច្នោះហើយក៏ដើរទៅទៀត ដើម្បីស្វែងរកបឹង ឬត្រពាំងជាទីស្ងាត់ ហើយដែលមានត្រីច្រើននោះ ។ វាដើរទៅដល់បឹងមួយជាទីស្ងាត់, នៅមាត់បឹងនោះមានដើមឈើធំ ៗដុះច្រូងច្រាង ដ៏មានម្លប់ត្រឈៃល្មមវាពឹងពួនខ្លួនវាបាន ។ ពេលនោះមានបុរសម្នាក់នៅចងសន្ទូចក្នុងបឹងនោះ មុនខ្លាទៅដល់ ។ ដោយចង់មើលឲ្យឃើញសន្ទូចខ្លួន ដែលរាយនៅឯនាយឆ្ងាយបានស្រួល បុរសនោះរាយសន្ទូចហើយ មិនឈរនៅនឹងដីទេ ទៅឡើងលើដើមព្រឹក្សាមួយធំខ្ពស់នៅសម្ងំតែម្នាក់ឯង មិនមាត់កឡើយ ។ ឯខ្លានោះ កាលបានទៅដល់ហើយក៏ដើរភ្លូកចុះភ្លូកឡើងរកដើមឈើនឹងឡើង ធ្វើដូចជាសត្វអក ។ បុរសឮសូរមើលទៅឃើញខ្លាកំពុងតែដើរ រួចទៅឡើងអង្គុយជ្រហម ៗលើចុងឈើហើយធ្វើសំឡេងត្រាប់តាមសត្វអកថា « អកអូរៗ » គាត់មិនហ៊ានមាត់ថាអ្វីទេ ចាំតែមើលហើយគិតថា « ខ្លានេះ វាឡើងចុងឈើនៅក្នុងបឹងដូច្នេះ តើវាគិតធ្វើអ្វីអេះ ? » យូរបន្តិចមានត្រីងើបឡើងស្រាប់តែខ្លានោះ ស្ទុះលោតប្រូង រួចផុសឡើងវិញឈ្លក់ទឹកឮសូរខក់ ៗ ។ បុរសនោះឃើញហើយសើច រួចស្រែកថា « ស្លាប់ទៅ ! អាខ្មោច ធ្វើអ្វីដូច្នោះ»។ ខ្លាឮមើលទៅឃើញបុរសនៅលើចុងឈើ ក៏មានសេចក្ដីអៀនខ្មាសខ្លាំងណាស់ ស្ទើរនឹងស្លាប់ខ្លួន ព្រោះមិនដែលបង់គំនិតដល់ម្លឹងសោះ រួចខ្លានឹកថា « ឥឡូវបុរសនេះឃើញអញតែម្នាក់ឯង បើគាត់ទៅដល់ផ្ទះសមគាត់នឹងនិយាយប្រាប់គេថែមទៀត គេនឹងកាន់តែដឹងច្រើនឡើង កើតមានកេរ្តិ៍ឈ្មោះអាក្រក់ណាស់ បើដូច្នោះអញសូកគាត់ កុំនិយាយប្រាប់នរណាតទៅទៀតឡើយ » ។ ខ្លាបាននិយាយអង្វរបុរសនោះ ជាពាក្យឱនលំទោនថា « ឱ ! អ្នកអើយ ! ខ្ញុំបានជាចាប់ត្រីធ្វើដូចជាសត្វអកទៅ វាមិនបានឯត្រី ទៅបានឯលង់ទឹក ស្ទើរនឹងស្លាប់ ខ្ញុំមានសេចក្ដីខ្មាសអៀនច្រើនណាស់ បើដូច្នោះសុំអ្នកអាណិតខ្ញុំ កុំនិយាយទៅណាមកណាទៅទៀត ខ្ញុំនឹងតបគុណឧបការៈអ្នក» ។ បុរសតបវិញថា « ខ្លាឯងឲ្យអ្វីអញ »។ ខ្លាថា «ខ្ញុំសន្យារកសត្វ មួយព្រឹកមួយៗ យកមកជូនអ្នកនៅទីនេះរាល់តែថ្ងៃ» ។ បុរសនោះក៏ព្រមព្រៀងទទួលពាក្យខ្លា រួចហើយវិលទៅផ្ទះអាត្មាវិញ, លុះព្រឹកឡើង មកទទួលយកសត្វអំពីខ្លានៅកន្លែងសន្យា ។ ខ្លាក៏ខាំសត្វយកមកឲ្យបុរសនោះ ជាប្រក្រតីមិនហ៊ានខាន ។ កាលបើបុរសនោះបានសត្វនាំយកទៅផ្ទះអាត្មា ច្រើនថ្ងៃពេកណាស់ នាងភរិយាឆ្ងល់ លុះវេលាយប់ក៏សួរដោយស្ងាត់ថា « អ្នកឯងធ្វើដូចម្ដេច ក៏បានសត្វរាល់ថ្ងៃម្ល៉េះ ? ម្ដងសត្វនេះម្ដងសត្វនោះ ជ្រូក

ក៏មាន ក្តាន់ក៏មាន ឈ្លូសក៏មាន » ។ ប្តីថា « អញដាក់អន្ទាក់ » ។ ប្រពន្ធថា « អន្ទាក់អ្វីក៏បាន មិនដែលខានដូច្នេះ ? អ្នកអើយ ! ប្អូនឲ្យត្រង់ទៅមើល » ។ បុរសនោះក៏ភ្លេចពាក្យសន្យាដោយស្មានថា ខ្លាកាលណាវានឹងមក ក៏ប្រាប់ប្រពន្ធតាមរឿងហេតុពីដើមដល់ចុង ។ ប្រពន្ធនោះក៏ជឿ ។ លុះព្រឹកឡើងបុរសទៅយកសត្វអំពីខ្លាដូចសព្វដង លុះទៅដល់ស្រាប់តែឃើញខ្លាអង្គុយជ្រហមៗចាំនៅកន្លែងនោះ ។ លុះបុរសដើរទៅដល់ខ្លាប្រាប់ថា « អើ ! បុរសឯងមកហើយ អញនៅចាំទេតើ ! អញនិងស៊ីឯង ត្បិតកាលនិយាយគ្នាមុននោះ អញហាមថា កុំឲ្យនិយាយប្រាប់គេតទៅទៀត អញសូកឲ្យសត្វមួយៗរាល់តែថ្ងៃ, ឥឡូវម្តេចក៏និយាយប្រាប់គេ ? »។ បុរសនោះក៏ភ័យភ្នែកស្លោ ឥតប្រកែកថាអ្វីទេ គ្រាន់តែអង្វរទៅខ្លាវិញថា « បងខ្លាឯង ស៊ីក៏ស៊ីចុះ ខ្ញុំមិនប្រកែកទេ បានជានិយាយទៅហើយ តែបើម៉្យ៉ូនឹងស្លាប់រស់ ខ្ញុំសូមទៅជួបប្រពន្ធសិននឹងបានប្រាប់ឲ្យគេដឹងផង» ។ ខ្លាក៏ព្រមថា « អើ ទៅក៏ទៅចុះ តែឲ្យឆាប់ត្រឡប់មកវិញអញស្ពោះទឹកមាត់ចាំ តែស្ងួតទឹកមាត់អញតាមទៅស៊ីទាំងប្តីទាំងប្រពន្ធ, ទុកធ្វើអី មនុស្សនិយាយមិនទៀង » ។ បុរសនោះក៏នៅទាំងសោកសៅក្នុងចិត្ត ព្រោះតែមាត់មិនជិត បានជាខ្លាវាស៊ី, ទៅដល់ក៏ប្រាប់ប្រពន្ធតាមរឿងហេតុនោះហើយថា « ឥឡូវនៅមិនបានទេ ត្បិតខ្លាវាចាំតែយូរ វានឹងមកស៊ីទាំងអស់គ្នា » ។ ប្រពន្ធក៏យំសោកស្រណោះគ្នាទៅវិញទៅមកស្តាយគំនិត ។ ប្តីក៏លាភរិយាចេញចាកគ្រឹះស្ថាន ដើរមកតាមផ្លូវយំបណ្តើរផង, ដល់ពាក់កណ្តាលផ្លូវ ប្រទះនឹងទន្សាយ ៗសួរថា « បុរសឯងដើរទៅណាយំផងដូច្នេះ មានទោសទុក្ខដូចម្តេច ? ។ បុរសនោះ ថ្លែងឲ្យទន្សាយស្តាប់សព្វគ្រប់ប្រការតាមហេតុនោះ ។



ទន្សាយឆ្លើយថា " ឱ ! បើដូច្នោះ ភ័យអ្វី បុរសឯងទៅរកតែចេក ១ ស្និតមក ទៅខ្លាចអ្វី អាខ្លាកំព្រើលនោះ »។ បុរសនោះត្រេកអរក៏ម្នីម្នារត់ទៅរកបានចេកមួយស្និត ហើយជូនទៅលោកសុភាទន្សាយថា « ខ្ញុំជូនលោក ! សុំឲ្យតែលោកសុភាជួយខ្ញុំឲ្យរស់ជីវិតផងចុះ តែបន្តិច ខ្លាវាតាមមកស៊ីខ្ញុំហើយ »។ សុភាទន្សាយថា « អើ ! អ្នកឯងទៅជាមួយនឹងយើង ចាំមើលខ្លានោះឲ្យជាក់ » ។ រួចសុភាទន្សាយរកដំបូកមួយយ៉ាងខ្ពស់ ឡើងទៅអង្គុយលើដំបូកនោះ ដើម្បីមើលទៅឲ្យបានឆ្ងាយ ។ ឯខ្លា កាលចាំបុរសនោះយូរពេក ក៏តាមមក ប្រាថ្នានឹងខាំស៊ីទាំងពីរនាក់ ព្រោះខុសសន្យាគ្នាពីរលើកហើយ, វាដើរម្នាក់ឯងតាមផ្លូវ រលេះរលាំងមកដល់ទៀបដំបូក ។ បុរសនោះឃើញ ក៏ប្តឹងសុភាទន្សាយថា « ហ្ន ! មកហើយលោក » ។ សុភាទន្សាយប្រាប់ថា« កុំមាត់ ! ចាំវាមកជិតសិន » ។ ខ្លាដើរមកកាន់តែជិត សុភាទន្សាយពមចេកមួយក្នុងមាត់ ហើយស្រែកគ្រហែមឡើងថា «អ៊ែម ៗស៊ីខ្លា ៥ មិនស្កាំផ្ទៃ ស៊ីត្រប់ខារប៉ុនកូនដៃស្អាកស្ទើរបែក អ៊ែម ៗ» ។ ខ្លាឮសំឡេងជំក្រអួនថា «ស៊ីខ្លា៥ មិនស្កាំផ្ទៃ» ក៏ស្ទុះថយក្រោយ ។ សុភាទន្សាយគ្រហែមថែមម្តងហើយម្តងទៀតយ៉ាងផ្អួនៗ ។ ខ្លាស្ទុះរត់លែងទាំងមើលក្រោយ រត់ឆ្ងាយទៅប្រទះស្វាមួយនៅលើចុងឈើ ស្វាឃើញខ្លារត់ស្រែកសួរថា «បងខ្លា រត់មានការណ៍អ្វី ?» ។ ខ្លាឮហើយឈប់ ឆ្លើយតបទៅវិញ «ទេ ! ទេ !វ៉ឺ អើយ ! អាណាក៏ជំម្លេះ ស៊ីខ្លាដល់ទៅ ៥ មិនឆ្អែត បានជាអញភ័យ រត់មកក្រែងវាស៊ី»។ ស្វាសួរថា « បងឯងឃើញដែរឬអ្វី ? ។ ខ្លាថា « ទេ ! ឮតែមាត់ » ។ ស្វាសួរថា « មាត់ត្រង់ណា ? »ខ្លាតបថា «នៅបៀតដំបូកឯដើមពង្រនោះណា» ។ ស្វាថា « ក្រែងបង






សុភាទេដឹង ? ចំណាំតែឃើញនៅត្រង់ហ្នឹង » ។ ខ្លាតបថា «មិនមែនទេ សម្តីសុភាណាដូច្នោះ» ។ ស្វាថា «ទេ ! ប្រាកដជាសុភាហើយ , បើដូច្នោះទៅម្តងទៀតមើល ខ្ញុំជូនទៅ » ។ ខ្លាមិនព្រមទៅថា « ក្រែងបងស្វាឯងរត់ចោលអញតែឯងភ័យរត់ឡើងចុងឈើទៅ, នៅតែអញម្នាក់ឯង ស្លាប់អញហើយ » ។ ស្វានិយាយម្តងទៀតថា បើបងឯងខ្លាចខ្ញុំរត់ចោល យើងចងកន្ទុយភ្ជាប់គ្នាខ្ញុំឡើងទៅចុងឈើឯណារួចបើបងជាប់នឹងខ្ញុំហើយ » ។ ខ្លាថាអើ ! បើដូច្នោះទៅក៏ទៅកុំរត់ចោលគ្នាវ៉ឺ ! ។ ខ្លានិងស្វាចងកន្ទុយជាប់គ្នាហើយ ដើរតម្រង់ទៅដំបូកនោះ ។ បុរសនោះឃើញប្តឹងសុភាទន្សាយទៀតថា « លោកអើយ ! មកទៀតហើយម្តងនេះ មានស្វាមកផង ខ្ញុំខ្លាចណាស់លោក! »សុភាទន្សាយថា « កុំបារម្ភអ្វី ! នៅមាត់ឲ្យស្ងៀម ចាំវាមកជិតបន្តិច នឹងមើលវា»។ សុភាទន្សាយ ក៏ប្រុងបកចេកមួយនឹងពមឲ្យមាំ ។ ដល់មកជិតស្វាសួរថាត្រង់ណាបងខ្លា ? ។ ខ្លាថា «ហ្ន ត្រង់ហ្នឹង, ហ្ន ! មាត់ស្រែកពីត្រង់នោះ » ។ សុភាទន្សាយពមចេកនៅក្នុង

មាត់ស្រែកថា « យើ ! អាស្វាក្រញាំ ជំពាក់បំណុលអញ ៤ – ៥ ឆ្នាំ ដឹកអាខ្លាសំគមមួយឲ្យអញ អ៊ែម ! មើលមារយាទអាស្វានេះ ! » ។ ខ្លាឮដូច្នោះ ក៏ស្ទុះរត់ភីងទៅ ស្វាឃាត់ពុំស្តាប់ ហើយគិតក្នុងចិត្តថា « យើអាស្វានេះ វានាំអញមកផាត់បំណុលទេតើ ! » ។ ស្វាស្រែកថា « បងខ្លា ឈប់សិន ៗ ខ្លាក៏មិនព្រម ដោយចូលចិត្តថា ច្បាស់ជាស្វាយកខ្លួនមកផាត់ឲ្យគេ » ហើយរត់ទៅឆ្វាយ ទាល់តែស្វានោះរណ្តំនឹងឈើ នឹងដី ស្លាប់ខ្លួនខូចអសារឥតការ ។

> ***មាត់មានគ្រប ដបមានឆ្នុក***

កម្ពុជសុរិយាលេខ ៤- ៥ – ៦ ឆ្នាំ ១៩៣៣ – ៤ ទំព័រ ២០១ រៀបរៀងដោយព្រះមេត្រីតេជោ សុគតោ ក្រមការដើមខ្សែលេខ ២ ។


g+1 +2 Recommend this on Google

Wunsch-Domains bei STRATO

Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

